## មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
## ខេត្តពោធិ៍សាត់

# វិធានការចម្រុះគ្រប់គ្រងដំណាំ
# លើដំណាំស្រូវ




រៀបរៀងដោយ លោកស្រី យឹម សុភី

អនុប្រធាន ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម


ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧


Email: ysophy168@gmail.com and 012 558 312




# វិធានការចម្រុះគ្រប់គ្រងដំណាំ លើដំណាំស្រូវ

វិធានការចម្រុះគ្រប់គ្រងដំណាំ លើដំណាំស្រូវ មាន កត្តា ២  សំខាន់:

1. វិធានការកំចាត់ដោយកត្តាធម្មជាតិ
2. វិធានការកំចាត់ដោយការប្រតិបត្ត

# ការកំចាត់ដោយកត្តាធម្មជាតិ (Natural Control)

បើមិនមានយន្តការការពារពីធម្មជាតិ:

i. បរិមាណប្រជាករកត្តាចង្រៃកើនច្រើន,

ii. មិនអាចគ្រប់គ្រង

ជាសកម្មភាពកើតឡើងពីការប្រមូលផ្តុំនៃ:

i. កត្តាបរិស្ថាន

ii. កត្តារូបសាស្ត្រ, ជីវសាស្ត្រ ដែលរក្សាបរិមាណប្រជាករកត្តាចង្រៃឲ្យនៅក្នុងកំរិតមួយខ្ពស់ ឬ ទាបជាងការកំណត់ក្នុងអំឡុងពេលមួយ

សមាសភាពសំខាន់ៗនៃវិធានការកំចាត់ដោយធម្មជាតិមាន:

i. កត្តាអាកាសធាតុ, ការផ្លាស់ប្តូរសម្ពាធបរិយាកាស

ii. ទីកន្លែង និងភាពអាចរកបាននៃអាហារ



# ការកំចាត់ដោយការប្រត្តបត្ត (Applied Control)

ជាការរួមបញ្ចូលគ្នានៃវិធានការជាច្រើនដែលបាន បង្កើតឡើងដោយមនុស្ស និង មានប្រសិទ្ធិភាពបំផុត ក្នុងការកំចាត់កត្តាចង្រៃ ។









វិធីសាស្រ្តសំខាន់ៗនៃការកំចាត់ដោយប្រត្តិបត្តមាន:

- វិធានការដាំដុះ
- វិធានការមេកានិច
- វិធានការរូបសាស្រ្ត
- វិធានការជីវសាស្រ្ត
- វិធានការគីមី និងវិធានការច្បាប់








# វិធានការដាំដុះ (Cultural control)

ប្រើវិធីសាស្ត្រដាំដុះផ្សេងៗដើម្បីៈ

- បង្កលក្ខណ្ឌមិនសមស្របសម្រាប់ការរស់នៅ
- ការលូតលាស់ និងការបន្តពូជរបស់កត្តាចង្រៃ

វិធីសាស្ត្រទាំងនោះមានដូចជាៈ

✓ ការភ្ជួររាស់

✓ ការកែប្រែពេលវេលាដាំដុះ

✓ ការដាំដំណាំឆ្លាស់ និង

✓ ការគ្រប់គ្រងទឹកជាដើម។ល។







# វិធានការមេកានិច (Mechanical control)

ការប្រមូល និងកំចាត់ដោយដៃនូវកត្តាចង្រៃមានដូចជាៈ

- ✓ សត្វល្អិតចង្រៃ, កណ្ដុរ, និងរុក្ខជាតិចង្រៃ
- ✓ ការប្រើសំណាញ់ផ្លាស្ទិក ឬរនាំងបាំង
- ✓ អន្ទាក់ភ្លើង, កន្ត្រងបក់







# វិធានការរូបសាស្ត្រ (Physical Control)

វិធានការនេះសំដៅលើការយកចេញ ឬបំផ្លាញចោលកត្តាចង្រៃដោយលក្ខណៈមេកានិចដោយប្រើកត្តារូបសាស្ត្រ ដូចជា: កំដៅ, ភាពត្រជាក់ សំណើម

## ឧទាហរណ៍:

- ✓ ទឹកក្តៅ និងថាមពលព្រះអាទិត្យ ត្រូវបានប្រើប្រាស់ជាញឹកញាប់សម្រាប់ស្ទេរីលគ្រាប់ដំណាំដែលមានមេរោគមុនយកទៅដាំ។
- ✓ ការហាលសំងួតគ្រាប់ធញ្ញជាតិ ដើម្បីឲ្យសំណើមគ្រាប់ស្ថិតក្នុងភាគរយសំណើមទាប មានសារសំខាន់ក្នុងការស្តុកទុក

# វិធានការជីវសាស្ត្រ (Biological Control)

ការកំចាត់កត្តាចង្រៃដែលធ្វើឡើងដោយ:

- ✓ ពពួកប្រេដាទ័រ
- ✓ ពពួកប៉ារ៉ាស៊ីត
- ✓ ភ្នាក់ងារបង្កមេរោគផ្សេងៗដែលមាននៅក្នុងតំបន់






# វិធានការគីមី (Chemical Control)

ថ្នាំកសិកម្មនៅតែបន្តជាឧបករណ៍គ្រឹះក្នុងការគ្រប់គ្រងកត្តាចង្រៃ
វិធានការគីមី ជាមធ្យោបាយមានប្រសិទ្ធភាពរហ័សក្នុងការកំចាត់កត្តាចង្រៃ

វិធានការចម្រុះគ្រប់គ្រងកត្តាចង្រៃ ជាការរួមបញ្ចូលគ្នារវាងវិធីសាស្ត្រខាងលើ ដោយមានការរៀបចំផែនការត្រឹមត្រូវ ដើម្បីកាត់បន្ថយបរិមាណប្រជាករកត្តាចង្រៃ ឬ រក្សាបរិមាណប្រជាករវាឲ្យស្ថិតក្នុងកំរិតទាបជាងកំរិតមួយដែលការខូចខាតដំណាំអាចទទួលយកបានជាលក្ខណៈសេដ្ឋកិច្ច

# ទិដ្ឋភាពច្បាប់ (Regulatory Control)

- ✓ មនុស្ស ⇨ កើតមាន និងផ្ទុះឡើងនៃកត្តាចង្រៃ
- ✓ ចរាចរទំនិញ ⇨ ឆ្លងរាលដាលកត្តាចង្រៃពីកន្លែងមួយទៅកន្លែងមួយថ្មីទៀត
- ✓ ដើម្បីជួយជំនះបញ្ហានេះ ⇨ ប្រទេសជាច្រើនត្រូវបានអនុមត្ត និងអនុវត្តនូវច្បាប់ និងបញ្ញត្តិផ្សេងៗស្ដីពីការដាក់ទីកន្លែង ឬសម្ភារៈដែលរងការបំផ្លាញ ឬមានផ្ទុកកត្តាចង្រៃឲ្យនៅដាច់ដោយឡែកពីគ្នា

# សមាសធាតុចំបងៗ នៃការគ្រប់គ្រងកត្តាចង្រៃ

តើវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) មានធាតុចំបងៗប៉ុន្មាន? អ្វីខ្លះ?

- ✓ ការកំចាត់ដោយធម្មជាតិ
- ✓ ការជ្រើសរើសសំណាក
- ✓ កំរិតទ្វារសេដ្ឋកិច្ច
- ✓ ចំណេះដឹងជាក់លាក់អំពីជីវវិទ្យា និងបរិស្ថានវិទ្យារបស់កត្តាចង្រៃសំខាន់ៗ នៅក្នុងប្រពន្ធ័បរិស្ថាន

**ការកំចាត់ដោយធម្មជាត** ?

ជាការទប់ស្កាត់ចំនួនប្រជាករកត្តាចង្រៃដែលមានរយៈពេលវែងដោយផ្អែកលើកត្តាបរិស្ថានធម្មជាតិទាំងស្រុង

# ការជ្រើសរើសសំណាក (Sampling)

## ហេតុអ្វីត្រូវជ្រើសរើសសំណាក?

- ✓ មធ្យោបាយប៉ាន់ប្រមាណចំនួនកត្តាចង្រៃ ដើម្បីផ្តល់ពត៌មានសម្រាប់ធ្វើការសម្រេចចិត្តក្នុងការគ្រប់គ្រង។
- ✓ ដឹងអំពីកំរិតទ្វារសេដ្ឋកិច្ច និងកំរិតប្រជាករកត្តាចង្រៃដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវនៅក្នុងវិធានការចម្រុះគ្រប់គ្រងដំណាំ
- ✓ មានវិធីសាស្រ្តជាច្រើនក្នុងការជ្រើសរើសសំណាកដំណាំដើម្បីប្រមូលទិន្នន័យកត្តាចង្រៃ និងទិន្នន័យការខូចខាតរបស់ដំណាំ។

## វិធីសាស្រ្តទាំងនោះរួមមាន:

- ការជ្រើសរើសដោយចៃដន្យ (by Random)
- ការជ្រើសរើសដោយបន្តបន្ទាប់ (Sequential)
- ការជ្រើសរើសដោយដៅចំណុច និងប្រើកង (by Point and trap Sampling)

# កំរិតទ្វារសេដ្ឋកិច្ច (Economic Threshold Level-ETL)

**កំរិតទ្វារសេដ្ឋកិច្ចជាអ្វី?**

- ✓ ជាការចង្អុលបង្ហាញបរិមាណប្រជាករកត្តាចង្រៃ ដែលបង្កការខូចខាត ស្មើនឹងតម្លៃនៃការការពារការខូចខាតនោះ (Headly 1972)

- ✓ កំរិតទ្វារសេដ្ឋកិច្ច ជាតម្លៃដែលមានការប្រែប្រួល អាស្រ័យលើកត្តាជាច្រើនដូចជា:

  - តម្លៃដំណាំលើទីផ្សារ
  - តម្លៃថ្នាំកសិកម្ម និងសម្ភារៈ
  - ការព្រួយបារម្ភពីគ្រោះថ្នាក់នៃការបំពុលបរិស្ថានរបស់អ្នកដាំ

# កំរិតមាត់ទ្វារសេដ្ឋកិច្ចសម្រាប់សត្វល្អិតចង្រៃលើដំណាំស្រូវនៅកម្ពុជា

| ដំណាក់កាលលូតលាស់ | សត្វល្អិតបំផ្លាញ | កំរិតមាត់ទ្វារសេដ្ឋកិច្ច | ការប្រើប្រាស់ថ្នាំពុលកំចាត់ (ធាតុផ្សំ/ទឹក ២០លីត្រ) |
|---|---|---|---|
| ៣ ទៅ ៥ | ទ្រីប | ស្លឹកបំផ្លាញ ២០% | Carbaryl (កាបារីល) |
| | ដង្កូវបំពង់កាត់ស្លឹក | ស្លឹកបំផ្លាញ ១៥% | Carbosulfan (កាបូស៊ុលហ្វេន),<br>Fipronil (ហ្វីប្រូនីល) |
| | មមាចត្នោត | កូនញាស់៥ក/ដ | Ethiprole (អេធីប្រូល)<br>Etofenprox (អេតោហ្វិនប្រុក) |
| | ដង្កូវស៊ីរូងដើម | ងាប់បណ្តូល ២០% | Chlorpyrifos (ក្លរពីរីហ្វូស) |

# កំរិតមាត់ទ្វារសេដ្ឋកិច្ចសម្រាប់សត្វល្អិតចង្រៃលើដំណាំស្រូវនៅកម្ពុជា

| ដំណាក់កាលលូតលាស់ | សត្វល្អិតបំផ្លាញ | កំរិតមាត់ទ្វារសេដ្ឋកិច្ច | ការប្រើប្រាស់ថ្នាំពុលកំចាត់ (ធាតុផ្សំ/ទឹក២០លីត្រ) |
|---|---|---|---|
| ៦ ទៅ ៩ | ដង្កូវមូរស្លឹក | បំផ្លាញស្លឹក ២០% | Bansultap (បេនស៊ុលថេប)<br>Carbosulfan(កាបូស៊ុលហ្វេន),<br>Fipronil(ហ្វីប្រូនីល) |
| | មមាចត្នោត | មេចំណាស់ស្លាបខ្លី/កូនញាស់ ៥ក/ដ | Ethiprole(អេធីប្រូល) ,<br>Dinotefuran (ឌីណូតេហ្វុយរ៉ាន),<br>Thiamitozam (ថេមីតូសេន) |
| | ដង្កូវស៊ីរូងដើម | ងាប់បណ្តូល ២០% | Chlorpyrifos(ក្លរពីរីហ្វូស) |

# កំរិតមាត់ទ្វារសេដ្ឋកិច្ចសម្រាប់សត្វល្អិតចង្រៃក្រោយពេលដាំក្នុងប្រទេសកម្ពុជា

| ដំណាក់កាលលូតលាស់ | សត្វល្អិតបំផ្លាញ | កំរិតមាត់ទ្វារសេដ្ឋកិច្ច | ការប្រើប្រាស់ថ្នាំពុល (ធាតុផ្សំ/ទឹក២០លីត្រ) |
|---|---|---|---|
| ១០ ទៅ ១៤ | ដង្កូវមូរស្លឹក | បំផ្លាញស្លឹក ១៥% | Bansultap, Carbosulfan, Fipronil |
| | មមាចត្នោត | កូនញាស់ ១០ក/គុម្ព | Ethiprole, Dinotefuran, Thiamitozam |
| | សង្កើចខ្មៅ | ០.៥ក/គុម្ព | Ethiprole, Clothianidin, Carbosulfan |
| ១៥ ទៅ ១៦ | ស្រឹងជញ្ជក់ | ៤ក/១ម៉ែត្រឡា | Carbosulfan |

# ទិដ្ឋភាពការគ្រប់គ្រងដំណាំ (IPM) លើដំណាំស្រូវ

- ✓ ស្រូវជាដំណាំស្បៀងសំខាន់ជាងគេ និងប្រើប្រាស់ជាអាហារសម្រាប់ប្រជាជនជាង ៤០% នៅលើពិភពលោក
- ✓ ស្រូវច្រើនជាង ៩០% ត្រូវបានផលិត និងប្រើប្រាស់នៅទ្វីបអាស៊ី
- ✓ ជាដំណាំអាចដាំបានយ៉ាងទូលំទូលាយក្រោមលក្ខណ្ឌ ក្សេត្រ អាកាសធាតុជាច្រើន
- ✓ ដើម្បីបំពេញតម្រូវការរបស់ពលរដ្ឋ, ពូជស្រូវដែលមានសក្តានុពលទិន្នផលខ្ពស់, ពូជធន់ទ្រាំនិងសត្វល្អិត, ជម្ងឺ និងធន់ទៅនិងការប្រែប្រួលនៃកត្តាគ្មានជីវិត ជាតម្រូវសំខាន់បំផុត។

# សត្វល្អិតស៊ីដំណាំស្រូវសំខាន់ៗ

## អ្វីជាសត្វល្អិតចង្រៃក្នុងវិស័យកសិកម្ម?

ជាពួកសត្វល្អិតមានឆ្អឹងកង និងគ្មានឆ្អឹងកង ដែលអាធ្វើការបំផ្លាញផលដំណាំដល់កំរិតទ្វាសេដ្ឋកិច្ច។

ឧទាហរណ៍:









# ភាពខុសគ្នារវាងពួកសត្វល្អិត និងពួកពីងពាង/ថៃ

## ពួកសត្វល្អិត

- ដងខ្លួនចែកចេញជា ៣ ផ្នែក
- មានជើង ៦ ឬ ៣ គូរ
- មានអង់តែន ២
- មានស្លាប ៤
- វដ្តជីវិត: ពង ដង្កូវ ដឹកដឿ និងសត្វពេញវ័យ
- របបអាហារ: ស្លឹក ផ្កា ដើម ឬស ផ្លែ គ្រាប់ និងរុក្ខរស (ពួកជញ្ជក់  បឺត)

## ពួកពីងពាង

- ដងខ្លួនចែកេចញជា ២ ផ្នែក
- មានជើង ៨
- គ្មានអង់តែន
- គ្មានស្លាប
- វដ្តជីវិត: ពង ដង្កូវ និងសត្វពេញវ័យ
- របបអាហារ: បឺត  ជញ្ជក់

# ផ្នែករបស់សត្វល្អិត/ ពួកពីងពាង







ពីងពាង/ចៃ

សត្វល្អិត

# សត្វល្អិតស៊ីស្រូវសំខាន់ៗ នៅកម្ពុជា

១. ដង្កូវហ្លូង
២. ដង្កូវមូរស្លឹក
៣. ដង្កូវបំពង់កាត់ស្លឹក
៤. ដង្កូវស៊ីរូងដើម
៥. មមាចខៀវ
៦. មមាចត្នោត
៧. ទ្រីបលើដំណាំស្រូវ
៨. មូសស្រូវ
៩. ស្រឹងលើដំណាំស្រូវ



# ដង្កូវហ្វូង (ARMYWORM_Wythimna separata)

មេអំបៅ និងដង្កូវ





Photo: Hoeung Hun

- មាន ៣ ប្រភេទ:
  - Rice swarming caterpillar
  - Common cutworm
  - Rice ear-cutting caterpillar
- មេអំបៅដង្កូវហ្វូងមួយអាចពងបានរាប់រយពងក្នុងមួយសំបុក
- សត្វមេមួយក្បាលអាចពងបានពី ៨០០ ទៅ ១០០០ ពង ក្នុងមួយជីវិត ដែលមានរយៈពេលប្រហែល ៧ ថ្ងៃ។

# លក្ខណៈជីវសាស្រ្តរបស់ដង្កូវហ្លូង

- ដង្កូវបំផ្លាញស្លឹកស្រូវគ្រប់ដំណាក់កាលលូតលាស់
- បំផ្លាញផ្នែកខាងលើនៃដើមស្រូវ នៅពេលត្រជាក់ មានពពកច្រើន ឬពេលយប់
- ដង្កូវមេអំបៅចូលចិត្តស្រែគ្មានទឹក។ ពេលថ្ងៃដង្កូវពួនក្នុងស្លឹកស្រូវ។
- ក្នុងស្រែគ្មានទឹក ដង្កូវសម្ងំនៅលើដីក្រោមដំទេចស្លឹក
- ដង្កូវក្លាយជាដឹកឡើនៅក្នុងដី, ប្រសិនបើក្នុងស្រែមានទឹក នោះដង្កូវក្លាយជាដឹកឡើនៅលើដើមស្រូវ

# វិធិសាស្រ្តវិធីដាំដុះ

ពេលខ្លះមិនអាចគេចផុតពីការផ្ទុះទ្បើងនូវជង្គូវហ្វូង។ ក្នុងករណីនេះយើងត្រូវៈ

- ការពន្លិចថ្នាលសំណាប គឺជាវិធីដ៏ល្អសំរាប់ការពារដង្កូវហ្វូង។
- ដាក់ផេះតាមចង្អូរជុំវិញស្រែ ដើម្បីការពារកុំឲ្យដង្កូវហ្វូងឆ្លងទៅកន្លែងផ្សេងៗ
- ការដាក់ផេះតាមចង្អូក៏ធ្វើជារបាំងការពារផងដែរកុំឲ្យដង្កូវចេញពីថ្នាលសំណាប នៅពេលដង្កូវហ្វូងមានការផ្ទុះទ្បើង

# វិធិសាស្រ្តជីវសាស្រ្ត

ចៀសវាងសំលាប់សត្វល្អិតមានប្រយោជន៍ (ដូចជា៖ ពួកឪម៉ាល់, ពីងពាង ។ល។)






# វិធីសាស្ត្រ គីមី

- ការប្រើថ្នាំពុល គួរតែជាជម្រើសចុងក្រោយសំរាប់ការការពារដង្កូវហ្វូង
- **ត្រូវគិតអំពីការគ្រោះថ្នាក់ដល់សុខភាព និងបរិស្ថាន**
- ត្រូវធ្វើការថ្លឹងថ្លែងឲ្យបានច្បាស់លាស់ដល់បញ្ហាសុខភាព និងបរិស្ថាន
- មុនសម្រេចចិត្តប្រើថ្នាំពុល ត្រូវពិគ្រោះយោបល់ជាមួយអ្នកបច្ចេកទេស ការពាកដំណាំ សម្រាប់ការណែនាំ តាមស្ថានភាពជាក់ស្តែងនៃដំណាំរបស់អ្នក
- ជាទូទៅត្រូវអានការណែនាំនៅជាប់និងដប ឬកញ្ចប់ថ្នាំឲ្យបានច្បាស់

# ដង្កូវមូរស្លឹក ( RICE LEAFFOLDER-Cnaphalocrocis medinalis)


Photo: Hoeung Hun

- មេអំបៅដង្កូវមូរស្លឹកមាន ពណ៌ត្នោតលឿង ប្រផេះ។
- ដង្កូវមូរស្លឹកស្លឹកស្រូវជុំវិញខ្លួន ដោយភ្ជាប់គែមស្លឹកស្រូវចូលគ្នាដោយសសៃឆ្មារពណ៌ប្រាក់
- មេអំបៅពងនៅពេលយប់។ វាទំលាក់ពងក្នុងរយៈពេល ១ ទៅ ២ ថ្ងៃបន្ទាប់បង្កាត់គ្នា។
- សត្វមេមួយក្បាលពងបានប្រហែល ៣០០ បងបានប្រហែល ៣០០ពង ក្នុងមួយជីវិតរយៈពេល ១០ ថ្ងៃ

# ការបំផ្លាញរបស់ដង្កូវម្ទូរស្លឹក





- ស្លឹកដែលរម្ទូរធ្វើឲ្យរាំងស្ទះដំណើរការធ្វើរស្មីសំយោគ
- ដង្កូវស៊ីបំផ្លាញជាលិកាលើនៃស្លឹក និងមានធ្នូតស
- មុនដំណាក់កាលកកើតកគួរ, ការបំផ្លាញស្លឹកប្រហែល ៥0% មិនធ្វើឲ្យប៉ះពាល់ដល់ការបាត់បង់ទិន្នផលទេ។
- ស្រូវងាយរងគ្រោះជាមួយដង្កូវម្ទូរស្លឹកពីដំណាក់កាលសំណាបដល់ចេញផ្កា
- ប្រសិនបើការបំផ្លាញស្លឹកអមគួរ (ស្លឹកទង់ជ័យ) កំរិត ៥0%, នោះនិងមានបាត់បង់ទិន្នផលយ៉ាងខ្លាំង។

# សត្រូវធម្មជាតិរបស់ដង្កូវម្សៅស្លឹក

ចំនួនសត្រូវធម្មជាតិបានកំរិតដង្កូវម្សៅស្លឹកឲ្យស្ថិតនៅក្រោមកំរិតមាត់ទ្វារសេដ្ឋកិច្ច។ មានប្រភេទជាច្រើននៃលំដាប់ៈ

- ✓ ពពួកផ្សិត  បាក់តេរី នឹងភ្នាក់ងារបង្ករោគមួយចំនួនទៀត។ល។
- ✓ ពពួកសត្វល្អិតជាអតិសុខុមប្រាណដូចជាៈ Bacillus thuringiensis មានប្រសិទ្ធិភាពខ្លាំងក្នុងការប្រឆាំងដង្កូវម្សៅស្លឹក
- ✓ សត្វឆ្អឹងកង ដូចជាៈ កង្កែប នឹងគីង្គក់ ត្រូវបានចាត់ទុកជាប្រេដាទ័រយ៉ាងសំខាន់សម្រាប់ដង្កូវម្សៅស្លឹក។

# ដង្កូវបំពង់កាត់ស្លឹក( CASEWORM-Nymphula depunctalis)




- មេអំបៅមានពណ៌សភ្លឺ និងមានចំណុចពណ៌ត្នោតព្រឿងៗ និងពណ៌ខ្មៅ
- ពងមួយ ឬជាកញ្ចុំនៅខាងក្រោមផ្ទៃស្លឹក
- ដង្កូវមានពណ៌ខៀវខ្ចី និងកបាលមានពណ៌ប្រផេះទឹកក្រូច
- ដឹកឌឿមានពណ៌ពងមាន់ បន្ទាប់មកក្លាយជាពណ៌ទឹកប្រាក់នៅពេលពេញវ័យ
- មេអំបៅពេញវ័យមានពណ៌ស ប្រផេះ ខ្លះឆ្នូត និងមានស្នាមអុតលើស្លាប

# ការបំផ្លាញរបស់ដង្កូវបំពង់កាត់ស្លឹក

ការបំផ្លាញមានសភាពខ្លាំងក្លាពេលស្រូវស្ថិតក្នុងដំណាក់កាលសំណាប រហូតដល់ដំណាក់កាលបែកគុម្ព

មេអំបៅធ្វើសកម្មភាពតែនៅពេលយប់, លាក់ខ្លួននៅក្រោមជម្រកស្លឹកស្រូវនៅពេលថ្ងៃ ដើម្បីលាក់ខ្លួនពីពពួកបក្សី នឹងកន្ទុំរុយប្រេដាទ័រ

ដង្កូវរបស់វារស់នៅខាងក្នុងបំពង់នៃស្លឹកស្រូវដែលវាកាត់ទំលាក់អណ្តែតលើផ្ទៃទឹក

ពួកវាឆ្លងទៅដើមផ្សេងៗទៀតដោយបណ្តែតខ្លួននៅក្នុងបំពង់ ទៅភ្ជាប់នឹងដើមស្រូវខ្ចីៗនៅខាងលើផ្ទៃទឹកបន្តិច

ដង្កូវស៊ីយកតែជាលិកាស្លឹក ដោយបន្សល់ទុកតែភ្នាសស្តើងៗនៅផ្នែកខាងក្រោមនៃស្លឹកប៉ុណ្ណោះ។

# សញ្ញានៃការបំផ្លាញរបស់ដង្កូវបំពង់កាត់ស្លឹក



Photo: Hoeung Hun

- កាត់ចុងស្លឹក ធ្វើបំពង់ស្លឹក
- មានរាងដូចកាំជណ្ដើរ
- ចេញស្នាមសឆ្នូតលើស្លឹក



# ដង្កូវស៊ីរូងដើមស្រូវ (RICE STEM BORER-Scirpophaga inscertulas)





Photo: Hoeung Hun

មានដង្កូវស៊ីរូងដើម ៥ ប្រភេទដែលជាកត្តាចង្រៃយ៉ាងសំខាន់លើដំណាំស្រូវនៅអាស៊ី:

- ✓ ដង្កូវស៊ីរូងដើមពណ៌លឿង
- ✓ ដង្កូវស៊ីរូងដើមពណ៌ឆ្នូត
- ✓ ដង្កូវស៊ីរូងដើមក្បាលខ្មៅ
- ✓ ដង្កូវស៊ីរូងដើមពណ៌ផ្កាឈូក និង
- ✓ ដង្កូវស៊ីរូងដើមពណ៌ស

➢ វដ្ដជីវិត ជម្រក ការគ្រប់គ្រង និងការបំផ្លាញរបស់ប្រភេទផ្សេងៗនៃដង្កូវមានលក្ខណៈប្រហាក់ប្រហែលគ្នា

# លក្ខណៈជីវសាស្ត្ររបស់មេអំបៅដង្កូវស៊ីរូងដើម

- ដង្កូវមេពំបៅរស់នៅក្នុងដើមស្រូវ
- ជាទូទៅដង្កូវមួយរស់នៅក្នុងដើមស្រូវមួយដើម
- មេអំបៅមានសកម្មភាពខ្លាំងនៅពេលយប់
- មេអំបៅមួយអាចពងបានរហូតដល់ ៣ សំបុក ក្នុងរយៈពេល ៧ ទៅ ១០ ថ្ងៃនៃជីវិតសត្វពេញវ័យ
- សំបុកពងរបស់មេអំបៅស៊ីរូងដើមពណ៌លឿងមានរាងមូល គ្របដុយសសៃពណ៌ប្រផេះ
- សំបុកនីមួយៗមានពងប្រហែល ១០០ ពង

# ការបំផ្លាញរបស់ដង្កូវស៊ីរូងដើម

- ដង្កូវស៊ីរូងដើម អាចបំផ្លាញគ្រប់ដំណាក់កាលចាប់។
- បំផ្លាញក្នុងដំណាំក់កាលតូច បណ្តូលចេញមកមានពណ៌ចំបើង និងងាប់។
- បើបំផ្លាញនៅពេលបន្ទាប់ពីកើតកក្ួរ នោះកក្ួរចេញមកមានពណ៌ស ឬស្កុក។
- ដង្កូវស៊ីរូងដើមមានផលប៉ះពាល់ខ្លាំងដល់ទិន្នផលស្រូវប្រពៃណី ព្រោះការងាប់កក្ួរពុំមានអ្វីមកជំនួសបានឡើយ





Photo: Hoeung Hun

# សត្រូវធម្មជាតរបស់ដង្កូវស៊ីរូងដើម

- ភាគច្រើននៃការកំចាត់លើដង្កូវស៊ីរូងដើមបានមកពីសត្រូវធម្មជាតិ ប្រេដាទ័រ  ប៉ារ៉ាស៊ីត និង មេរោគបង្ករជម្ងឺលើត្នល្អិតដែលមានស្រាប់នៅក្នុងតំបន់។
- មានពពួកប៉ារ៉ាស៊ីតលើពងដង្កូវីរូងដើមសំខាន់ជាងគេ ៣ ប្រភេទៈ
  - Telenomus
  - Tetrastichus
  - Trichogramma
- ឪម៉ាល់ Tetrastichus អាចពងដាក់ក្នុងពងដង្កូវស៊ីរូងដើម ក្រោយមកនឹងត្រូវគ្របដោយ រោមសំឡី
- ឪម៉ាល់ Telenomus ធ្វើប៉ារ៉ាស៊ីតលើពងដង្កូវស៊ីរូងដើម ខណៈពេលមេអំបៅកំពង់ធ្វើ សកម្មភាពពង មុនពេលគ្របដោយរោមសំឡី

# សត្រូវធម្មជាតរបស់ដង្កូវស៊ីរូងដើម

- បណ្តុំពងរបស់មេអំបៅស៊ីរូងដើម ជាចំណីអាហាររបស់ប្រេដាទ័រជាច្រើន ដូចជា:
  - កណ្តូបអង់តែនវែង (Conecephalus longipennis) ស៊ីពងដង្កូវស៊ីរូងដើមពណ៌លឿងមិនចេះស្កប់ស្កល់
  - ពួកចង្រិត (Metioche vattaticollis and Anaxipha longipennis) ស៊ីពងរបស់ដង្កូវស៊ីរូងដើមផ្ទួតជាងាហារ
  - ស្រឹងគោកក៏វាយប្រហាលើពងរបស់ដង្កូវស៊ីរូងដើផ្ទួតផងដែរ
- មានប្រេដាទ័រផ្សេងៗទៀតវាយប្រហាដង្កូវស៊ីរូងដើមពេលនៅតូចៗ ដូចជា:
  - ពួកអណ្តើកមាស (Coccinellid beetle, harmonia octomaculata)
  - ពួកខ្ទួតដី (Carabid beetle)
- ដង្កូវតូចៗធ្លាក់ទឹកត្រូវក្លាយជាចំណីរបស់ស្រឹងទឹក
- មេអំបៅត្រូវបានចាប់ស៊ីដោយពួកពីងពាងខណ:ពេលវាទុំលើស្លឹកស្រូវ

# មមាចត្នោត (BROWN PLANTHOPPER-Nilapavarta lunges)



- ជាសត្វល្អិតមានរាងតូចពណ៌ ត្នោត ប្រផេះ។ មានលក្ខណៈខុសៗគ្នាៈ
  - មមាចត្នោតមានស្លាបវែង
  - មមាចត្នោតខ្លងស, កើតមាននៅពេលខ្វះអាហារ ឬ មានប្រជាករច្រើន
  - ពួកមានស្លាបមិនពេញលេញ
- មមាចត្នោតស្លាបវែងពេញវ័យអាចធ្វើការបម្លាស់ទីបានរាប់រយគីឡូម៉ែត្រ
- ពួកមមាចស្លាបវែងជាអ្នកបម្លាស់ទីដំមានសក្កានុពល និងជាអ្នកទទួលខុសត្រូវក្នុងកាបម្លាស់ទៅកន្លែងថ្មី

# លក្ខណៈជីវសាស្ត្ររបស់មមាចត្នោត

- មេពេញវ័យចាប់ផ្ដើមដោយញីឈ្មោលនៅពេលដែលវាវិវត្តពេញវ័យ ហើយផ្ដើមទំលាក់ពងនៅថ្ងៃបន្ទាប់ពីពាក់គ្នា
- សត្វញីមានស្លាបមិនពេញលេញអាចទំលាក់ពងបានពី ៣០០ ដល់ ៣៥០ ពង
- ចំនួនពងមានការប្រែប្រួលតាមលក្ខណ្ឌ័អាកាសធាតុ និងពងញាស់មានរយៈពេលប្រហែល ៦ ទៅ ៩ ថ្ងៃ។
- រយៈពេលនៃដំណាក់កាលកូនញាស់ប្រែប្រួលខុសៗគ្នាតាមលក្ខណ្ឌ័ចំណីអាហារ ដង់ស៊ីតេកំឡុងពេលលូតលាស់ និងកត្តាបរិស្ថា។
- តំបន់ត្រូពិចចាប់ពីញាស់រហូតដល់ពេញវ័យមានរយៈពេលពី ១០ ទៅ ១៥ថ្ងៃ
- សីតុណ្ហភាពសមស្របដល់ការលូតលាស់មមាចត្នោតមានពី ២៨ ដល់ ៣០អង្សាសេនៅបេលថ្ងៃ និងពេលយប់ត្រជាក់ជាងនេះបន្តិច។
- លក្ខណ្ឌ័អាកាសធាតុក្ដៅ និងសើម មមាចត្នោតមានសកម្មភាពពេញ ១ឆ្នាំ

# ការបំផ្លាញរបស់មមាចត្នោត

- ជញ្ជក់រុក្ខរសពីដើមស្រូវ និងបន្ថយការធ្វើរស្មីសំយោគសម្រាប់ផ្គត់ផ្គង់ចំណី
- មមាចចូលចិត្តជញ្ជក់រុក្ខរសពីដំណាំដែលប្រើប្រាស់ជីអាហ្សូតខ្ពស់
- ថ្នាំសម្លាប់សត្វល្អិតជាកត្តាចំបងមួយទាក់ទងនិងការផ្ទុះឡើងរបស់មមាចត្នោត
- មមាចត្នោតចូលចិត្តបំផ្លាញលើស្រែពឹងទឹកភ្លៀង និងស្រែស្រោចស្រពទំនាប
- មមាចត្នោតចូលចិត្តបំផ្លាញស្រែពង្រោះជាងស្រែសន្ទូង
- មមាចបំផ្លាញនៅគ្រប់ដំណាក់កាលលូតលាស់របស់ដំណាំ
- កូនទើបញាស់ និងសត្វពេញវ័យស៊ីបំផ្លាញនៅផ្នែកខាងគល់នៃដើមស្រូវ
- ធ្វើឲ្យស្រូវប្រែជាពណ៌ត្នោត និងធ្វើឲ្យស្រូវស្ងួតក្រៀមយ៉ាងរហ័ស ងាប់
- ការបំផ្លាញដំបូងមានពណ៌លឿង តែក្រោយមកក្លាយជាពណ៌ត្នោត។ លក្ខណ្ឌ បែបនេះ ហៅថា **ឆេះស្លឹកដោយមមាច**
- មានការបាត់បង់ទិន្នផល និងខូចខាតទាំងស្រុងបើការបំផ្លាញមានសភាពធ្ងន់ធ្ងរ
- ជាភ្នាក់ងារចម្លងជម្ងឺវីរុស (តឿស្មៅ, តឿរួញស្លឹក, ស្រពោនស្លឹក)។ល។

# សត្រូវធម្មជាតិរបស់មមាចត្នោត

- ប្រេដាទ័រ ប៉ារ៉ាស៊ីតនិងពួកបង្ករោគជាច្រើនបានបំផ្លាញមមាចត្នោតនៅគ្រប់ដំណាក់កាល និងមានប្រសិទ្ធិភាពក្នុងការកំចាត់ពួកវានៅគ្រប់ស្ថានភាព។
- ការប្រើថ្នាំសម្លាប់សត្វល្អិតមិនបានសមស្រប អាចសម្លាប់សត្រូវធម្មជាតិ និងនាំឲ្យមានការផ្ទុះឡើងយ៉ាងធ្ងន់ធ្ងររបស់កគ្តាចង្រៃ។
- ពងមមាចត្នោតត្រូវបានធ្វើប៉ារ៉ាស៊ីតកម្មដោយឪម៉ាល់ mymarid, trichogrammatid and eulophid (tetrastichus)
- ពួកស្រឹងគោក Mirid bug, phytoseiid mite ស៊ីបំផ្លាញពងមមាច
- មានប្រេដាទ័រស់នៅក្នុងទឹកជាច្រើនទៀតដូចជាៈ កន្ធេះឡង់, និងប្រេដាទ័រហែលលើផ្ទៃទឹក ដូចជាៈ ស្រឹងទឹក
- ពួកខ្ចូតដី, កន្តុំរុយ និងពីងពាងចចក ស្វែងរកកូនញាស់ និងមេចំណាស់យ៉ាងសកម្មដែលនៅលើស្លឹកស្រូវ

# មមាចខៀវ (GREEN LEAFHOPPER-Nephotettis virescens)



- មានមមាចខៀវ ៤ ប្រភេទៈ
  - N. Verescens, N. nigropectus
  - N. Malyanus, N. cinticep
- ការលូតលាស់របស់មមាចទាំងអស់នេះមានរយៈពេលដូចគ្នា
- កូនញាស់ និងមេពេញវ័យអាចចម្លងជម្ងឺវីរុសសំខាន់ៗមួយចំនួន
- វត្តមានមមាចខៀវមានច្រើននៅក្នុងរដូវវស្សា និងលើដំណាំស្រូវដែលមានសភាពលូតលាស់ល្អ
- មេចំណាស់អាចហើរបានក្នុងរយៈចម្ងាយឆ្ងាយរហូតដល់ ៦គ.ម

# ការបំផ្លាញរបស់មមាចខៀវ

- នៅពេលប្រជាកររបស់វាខ្ពស់ ពួកវាអាចបំផ្លាញដំណាមស្រូវដោយផ្ទាល់តែម្តង
- កូនញាស់ និងមេចំណាស់ជញ្ជក់រុក្ខរសពីស្លឹក និងបណ្តូលដោយប្រើមាត់ចុច
- មេចំណាស់ស៊ី និងរស់នៅផ្នែកខាងលើនៃដើមស្រូវ និងធ្វើឲ្យស្រូវដំណាំក្រិន
- ផលប៉ះពាល់ធ្ងន់ធ្ងរជាងការបំផ្លាញផ្ទាល់ គឺការចម្លងជម្ងឺវីរុស ដែលធ្វើទ្បើងដោយកូនញាស់ និងមេពេញវ័យ
- សត្វញីពងបានរាប់រយនៅក្នុងរយៈពេលនៃជីវិតជាមធ្យម ៣ សប្តាហ៏
- សត្វញីចូលចិត្តពងនៅលើដំណាំខ្ចីៗ ជាសំបុកមានពី ៨ ទៅ ១៦ ពង នៅលើស្រទបស្លឹក ឬលើទ្រនុងស្លឹកផ្នែកខាងក្រោមនៃដើមស្រូវ
- កូនញាស់មានវត្តមានច្រើននៅពេលល្ងាច

# សត្រូវរបស់មមាចខៀវ

- មមាចខៀវអាចត្រូវកំរិតចំនួនឲ្យនៅក្នុងកំរិតមួយបាន ដោយសារការធ្វើសកម្មភាពរបស់ប្រេដាទ័រ, ប៉ារ៉ាស៊ីត និងពួកបង្ករោគ
- ពងត្រូវបានស្រឹងគោកស៊ី និងធ្វើប៉ារ៉ាស៊ីតកម្មដោយឪម៉ាល់ Trichogrammatid and mymarid wasps
- កូនញាស់រងប៉ារ៉ាស៊ីតកម្មដោយរុយប៉ារ៉ាស៊ីត pipunculid flies, dryinid wasps
- ប្រេដាទ័រមួយចំនួនដូចជាៈ ស្រឹងទឹកជើងវែង, ស្រឹងទឹកកំប៉ោង, រុយចោរ, កន្ធុំរុយតូច, កន្ធុំរុយធំ, និងពីងពាង។ល។

# ទ្រីប លើដំណាំស្រូវ ( RICE THRIPS-Stenchaetothrip biformis)







- ទ្រីប ជាសត្វល្អិតចង្រៃដែលភាគច្រើនបំផ្លាញដំណាំស្រូវនៅតូចៗទើបនឹងដុះ។
- មាន ២ ប្រភេទ: មានស្លាប និង គ្មានស្លាប
- វដ្តជីវិតខ្លី និងបង្កើតចំនួនបានច្រើនអាចបំផ្លាញលើផ្ទៃដីដ៏ធំក្នុងរយៈ ២ ឬ ៣ ថ្ងៃ
- ទ្រីបអាចបង្ករការបំផ្លាញទាំងលើស្រូវទំនាប និងខ្ពង់រាប
- មេចំណាស់អាចរស់បានប្រហែល ២០ ថ្ងៃ និងអាចពងបានប្រហែល ២៥ ពងក្នុងមួយវដ្តជីវិតរបស់វា
- ពងវាញាស់ក្នុងរយៈពេល៣ ថ្ងៃបន្ទាប់ពីធ្លាក់ពង

# លក្ខណៈជីវសាស្រ្តរបស់ទ្រីប

- សត្វពេញវ័យជាទូទៅមានការបង្កកំណើតក្នុងរយៈ ៣ ទៅ ៤ ថ្ងៃបន្ទាប់ពីញាស់
- ពងចាក់បញ្ចូលក្នុងកោសិកាស្លឹកផ្នែកខាងលើក្នុងចំនួនពី ១៤ ទៅ ២៤ ពង។
- ដង្កូវក្លាយជាដឹកឌឿ និងញាស់នៅក្នុងរម្ងូរស្លឹក
- កូនតូចមានស្លាបខ្លី និងមិនមានសកម្មភាពទេ។ សត្វពេញវ័យមានរាងតូចទ្រវែង ពណ៌លឿងទៅខ្មៅប្រផេះ
- វដ្តជីវិតៈ ពីពង ដល់ សត្វពេញវ័យមានរយៈពេល ១០ ទៅ ១២ ថ្ងៃ ក្នុងលក្ខណ្ឌធម្មតា និងសីតុណ្ហភាពពេលថ្ងៃ ២៧អង្សា និងពេលយប ២៤អង្សាសេ
- ទ្រីបមានការលូតលាស់ខ្លាំងក្នុងខែកក្កដា ដល់ខែកញ្ញា និង ខែមករាដល់ ខែមិនា ឬនៅពេលមានភ្លៀងតិចតួច ឬគ្មានភ្លៀង។
- វគ្គមានផ្ទុះឡើងតាមរដូវរបស់ទ្រីប មានភាពខុសគ្នាតាមតំបន់ដោយសារការផ្លាស់ ប្តូររដូវ និងពេលវេលានៃការដាំដុះ

# ការបំផ្លាញរបស់ទ្រីប

ធ្វើឲ្យដាច់/ខូចជាលិកាបៃតងនៃស្លឹក

ស្លឹករងការបំផ្លាញមានពណ៌ឆ្នូតទឹកប្រាក់ ឬលឿង, រួញចេញពីគែម ទៅទ្រនុងកណ្តាលនៃស្លឹក

ក្នុងករណីបំផ្លាញធ្ងន់ធ្ងរស្រូវមានសភាពក្រិន ស្វិតសត្វពេញវ័យបំលាស់ទីពេលថ្ងៃរកកន្លែងស្រែមានស្រូវទើបស្ទូងឬថ្នាលសំណាប។

កូនទើបញាស់ស៊ីលើស្លឹក និងគល់ស្រទបស្លឹកខ្ចី

ដំណាំស្រូវដែលបានស្ទូងមុនរដូវភ្លៀង និងក្លាយជាគោលដៅចំបងក្នុងការបំផ្លាញរបស់ពពួកទ្រីប

រដូវភ្លៀងដែលអូសបន្លាយរយៈពេលវែង និងភ្លៀងធ្លាក់ខ្លាំងអាចជួយបន្ថយចំនួនប្រជាកររបស់ទ្រីប



# មូសផ្លុង (RICE GALL MIDGE-Orseola oryzae)



- មូសផ្លុងមានរាងតូចៗ ដូចសត្វមូសធម្មតា
- មូសញីមានពណ៌ក្រហមព្រឿងៗនិងមូសមានពណ៌ត្នោតលឿង
- មូសពេញវ័យមានសកម្មភាពខ្លាំងនៅពេលយប់ កើតមានតាមរដូវ ជាសត្វចូលចិត្តភ្លើង
- កើតមានច្រើននៅពេលអាកាសធាតុមានពពកច្រើន ឬមានភ្លៀងច្រើន
- សត្វមេ មួយក្បាលអាចពងបាន ពី ១ ទៅ ៤ពងនៅលើផ្ទៃខាងលើនៃស្លឹក
- វដ្តជីវិតមានរយៈពេល ៤ ទៅ ៥ ថ្ងៃចាប់ពីសត្វពេញវ័យ និងអាចពងបានប្រហែលជាំ ១០០ ពង។

# ការបំផ្លាញរបស់មូសផ្លុង

- មូសផ្លុងបំផ្លាញស្រូវចាប់ពីដំណាក់កាលសំណាប ដល់ចុងបញ្ចប់ដំណាក់កាលបែកគុម្ព
- កូនរបស់វាគ្មានជើងនិងស៊ីបំផ្លាញស្រូវដែលកំពង់លូតលាស់ ដើមស្រូវមានស្នាមប៉ោង
- សញ្ញានៃការបំផ្លាញស្លឹកបណ្តូលមានពណ៌ទឹកប្រាក់រាងជាបំពង់ ឬ ហៅថាស្លឹកខ្ទឹម ហើយមិនអាចបង្កើតក្មួរបានទេ
- នៅកម្ពុជា មានខេត្តដូចជាៈ ស្វាយរៀង, កំពត, ព្រៃវែង និងកំពង់ចាម ទទួលរងការបំផ្លាញដោយ មូសស្រូវខ្លាំង ជាងខេត្តដទៃ**(ក.ក.ស)**



# សត្រូវធម្មជាតិរបស់មូសផ្លុង

- ✓ មានប្រេដាទ័រមួយប្រភេទ Phytoseiit mite បំផ្លាញពងរបស់មូសផ្លុង
- ✓ មានពួកឪម៉ាល់ជាច្រើនប្រភេទ ដូចជា: platygasterid, eupalmid and pteromalid wasps ធ្វើប៉ារ៉ាស៊ីតកម្មលើពង និងមានពីងពាងចាប់មេពេញវ័យជាចំណី

# ស្រឹងជញ្ជាក់ស្រូវ (RICE BUG-Leptocorisa oraturius)





Photo: Hoeung Hun

- ស្រឹងជញ្ជក់ទឹកោះមាននៅក្រប់បរិស្ថាដំណាំស្រូវដែលពឹងផ្អែកទឹកភ្លៀង និងតំបន់ខ្ពង់រាប។
- ជាសត្វរាត្រីចរ មានសកម្មភាពខ្លាំងនៅពេលព្រឹកព្រលឹម និងនៅពេលល្ងាច។
- សត្វឈ្មោលអាចធ្វើការបន្តពូជបានភ្លាមបន្ទាប់ពីក្លាយជាសត្វពេញវ័យ ប៉ុន្តែសត្វញី ៧ ទៅ ១៤ ថ្ងៃក្រោយពេលពេញវ័យ
- ការពាក់គ្នាធ្វើឡើងនៅតែពេលព្រឹកព្រលឹម និងកម្រ ធ្វើឡើងនៅពេលយប់ណាស់
- ស្រឹងញីមួយក្បាលអាចពងបានពី ២៥០ ទៅ ៣០០ពង តម្រៀបជា ២ ឬ ៣ជួរតាមបណ្តោយចាងលើទ្រនុងស្លឹកស្រូវ

# ការបំផ្លាញរបស់សត្វស្រឹងជញ្ជក់ទឹកដោះ



Photo: Hoeung Hun

- កំរិត និងប្រភេទនៃការបំផ្លាញរបស់ស្រឹងជញ្ជក់ទឹកដោះ គឺអាស្រ័យនិងដំណាក់កាលលូតលាស់របស់ស្រូវ និងលក្ខណ្ឌ័បរិស្ថានផ្សេងៗ
- ជញ្ជក់គ្រាប់ស្រូវនៅដំនាក់កាលចេញផ្ការហូតដល់ដាក់ទឹកដោះ
- ការបាត់បង់សារធាតុស្តុកពីគ្រាប់ស្រូវ ធ្វើឲ្យគ្រាប់ស្រូវស្កៀត ឬគ្រាប់មិនពេញ និងមានស្នាមបំផ្លាញ
- ស្រឹងជញ្ជក់ទឹកដោះមានសកម្មភាពខ្លាំនៅពេលរបបខ្យល់មូសុងចាប់ផ្ដើម
- នៅពេលគ្រាប់ស្រូវប្រមាណ ៨០%ចាប់ផ្ដើមទុំ មេចំណាស់នឹងផ្លាស់ទីទៅស្រែដែលមានស្រូវនៅខ្ចី

# សត្រូវធម្មជាតិរបស់ស្រឹងជញ្ជក់ទឹកដោះ

- ប៉ារ៉ាស៊ីត និងប្រេដាទ័រជាច្រើន ជាសត្រូវធម្មជាតិរបស់ស្រឹងជញ្ជក់ទឹកដោះនៅគ្រប់ដំណាក់កាលលូតលាស់របស់វា។
- ឪម៉ាល់ប៉ារ៉ាស៊ីត scelionid wasps ធ្វើប៉ារ៉ាស៊ីតកម្មលើពង និង
- ប្រភេទឪម៉ាល់ប៉ារ៉ាស៊ីតជាច្រើនទៀតប្រហាលើស្រឹងបៃតង (stinkbug)
- កណ្តូបអង់តែនវែងស៊ីពងស្រឹង
- មានពីងពាងជាច្រើនប្រភេទចាប់កូនញាស់ និងមេចំណាស់ស៊ី។ ដូចជាពីងពាង:
  - ពីងពាងសំណាញ់,
  - ពីងពាងថ្គាមវែង
- ពួកបង្គរោគមួយចំនួនទៀតដែលបំផ្លាញទៅលើកូនញាស់ និងមេចំណាស់

# ប្រដាទ័រសំខាន់ៗ លើដំណាំស្រូវ

អណ្តើកមាស Micrapis sp, Micraspis crocae







អណ្តើកមាស Harmonia octomaculata





# ខ្មូតដី Ophionea nigofasciata



# ស្រឹងគោក Mirid bug



# កន្ទុំរុយតូច Damselflies





# ពីងពាងចចក **Wolf spider** ***Lycosa pseudoannulata***



# ពីងពាងជើងបន្លា  lynx spiders






# ពីងពាងថ្គាមវែង   long-jawed spider



# រុក្ខជាតិស្រែសំខាន់ៗ លើដំណាំស្រូវ

កក់ឆត្រផ្កាតូច Cyperus difformis





# កក់ជ្រង់ *Cyperus iria*





# *ស្មៅក្រវាញជ្រូក Cyperus rotundus*





# ស្មៅពុកបង្កង *Digitaria ciliaris* (Retz)





# សម្មៅស្រូវ *Echinochloa colona*







# ស្មៅបែកក្បាល *Echinochloa crus-galli*





# ស្មៅជើងក្រាស់ *Eleusine indica*





# កក់ភ្នែកក្ដាម *Fimbristylis miliacae*







# ត្រកួន *Ipomoea aquatica* Forsk





# ស្មៅកង ឬស្មៅចំពុះទា *Ischaemum rugosum* Salisb.¦





# ស្មៅកន្ទុយដំរី *Leptochloa chinensis*

  

# ប្រចាំ *Monochoria vaginalis*







# នាងទាវ *Sphenochlea zeylanica*







# អរគុណ

ចំពោះការយកចិត្តទុកដាក់

របស់យើងទាំងអស់គ្នា





